សង្ខេបសម្រាប់
គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ ២០១១ លេខ ១៤

# អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យក្នុងប្រព័ន្ធនយោបាយបែបកូនកាត់៖ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងបរិបទប្រទេសកម្ពុជា[១]

*ដោយ ហេង សីហា គឹម សេតារា និង សូ សុខប៊ុនធឿន*[២]

*អត្ថបទសង្ខេបគោលនយោបាយនេះ ផ្តល់ជាទស្សនៈរួមមួយពីដំណើរការនៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា ក្នុងការជំរុញអភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅកម្រិតមូលដ្ឋាន គិតតាំងពីពេលចាប់អនុវត្តវិមជ្ឈការក្នុងឆ្នាំ២០០២ មក។ វិមជ្ឈការធ្វើឲ្យរដ្ឋាភិបាលខិតមកកៀកប្រជាពលរដ្ឋ ហើយជាទូទៅគេសន្មតថា វិមជ្ឈការជួយពង្រឹង (១) គណនេយ្យភាព និងការឆ្លើយតបរបស់រដ្ឋាភិបាល (២) ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍមូលដ្ឋាន និង (៣) ភាពជាតំណាងឲ្យប្រជាពលរដ្ឋ ហើយទាំងអស់នេះមានសារៈសំខាន់សម្រាប់អភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន។ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្តល់ការវាយតម្លៃពីកម្រិតដែលវិមជ្ឈការបានជួយដល់កត្តាជំរុញលទ្ធិប្រជាធិបតេយ្យ ព្រមទាំងផ្តល់នូវទស្សនវិស័យអំពីសមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈមនានាដែលត្រូវដោះស្រាយ ដើម្បីពង្រឹងវិមជ្ឈការតាមបែបប្រជាធិបតេយ្យនៅកម្ពុជា។*

## សេចក្តីផ្តើម

កំណែទម្រង់វិមជ្ឈការ បានចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ២០០២ ក្នុងរូបភាពផ្តល់ស្វ័យភាពដល់ថ្នាក់មូលដ្ឋាន (ឃុំ/សង្កាត់) ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អនុម័តក្នុងឆ្នាំ២០០១។ មកទល់បច្ចុប្បន្ន ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ បានធ្វើឡើងចំនួន ២លើក ប្រកបដោយជោគជ័យ ក្នុងឆ្នាំ២០០២ និង ២០០៧។ កំណែទម្រង់នេះ ត្រូវបានពង្រីកវិសាលភាពកាន់តែធំដល់ថ្នាក់ក្រោមជាតិ តាមក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលអនុម័តក្នុងឆ្នាំ២០០៥។ ស្របតាមក្របខ័ណ្ឌនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ហៅថា ច្បាប់រៀបចំអង្គការ) ត្រូវបានអនុម័តក្នុងខែមេសា ២០០៨។ ច្បាប់រៀបចំអង្គការនេះ បានបង្កើតឲ្យមានរដ្ឋបាលថ្នាក់ក្រោមជាតិ ២ថ្នាក់បន្ថែមទៀត គឺក្រុមប្រឹក្សាខេត្ត និងក្រុមប្រឹក្សាក្រុង/ស្រុក។ ក្រុមប្រឹក្សាទាំងនេះ ទទួលបានតំណែងតាមការបោះឆ្នោតដោយប្រយោលពីក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលបានធ្វើឡើងជាលើកដំបូងក្នុងខែឧសភា ២០០៩។ នៅក្នុងកំណែទម្រង់ដ៏ស៊ីជម្រៅនេះ ធនធាន សិទ្ធិអំណាច និងមុខងារសំខាន់ៗ ត្រូវបានធ្វើប្រតិភូកម្មពីថ្នាក់កណ្តាល ទៅឲ្យថ្នាក់ខេត្ត និងថ្នាក់ក្រុង/ស្រុក ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការផ្តល់សេវាក្រោមក្របខ័ណ្ឌរដ្ឋបាលឯកភាព។ លើសពីនេះទៀត យន្តការសម្រាប់គណនេយ្យភាព ការចូលរួមពីសាធារណជន ភាពជាតំណាង ប្រសិទ្ធភាពការងារ ប្រជាធិបតេយ្យ និងការអភិវឌ្ឍមូលដ្ឋាន ក៏ត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្តផងដែរ (RGC 2005)។

ទោះបីការអនុវត្តក្របខ័ណ្ឌច្បាប់នៃកំណែទម្រង់វិមជ្ឈការ បានជឿនលឿនទៅមុខក្តី ក៏នៅមិនទាន់មានការត្រួតពិនិត្យជាប្រព័ន្ធអំពីជោគជ័យសំខាន់ៗ ដែលសម្រេចបានមកទល់បច្ចុប្បន្ននោះទេ។ ការសិក្សាពីមុនៗ បានផ្តល់គំនិតខុសៗគ្នាអំពីការសម្រេចបាន និងអនាគតនៃកំណែទម្រង់ ពោលគឺបានបង្ហាញត្រឹមតែមួយភាគនៃអ្វីដែលកើតមានឡើងជាក់ស្តែងប៉ុណ្ណោះ។ ការសិក្សាកន្លងមកនេះ អាចបែងចែកជា ២ក្រុមធំៗ។

ក្រុមទី១ អះអាងថា កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) មិនបានសម្រេចតាមការរំពឹងទេ ពីព្រោះមិនស្របទៅនឹងបរិបទវប្បធម៌នយោបាយនៅកម្ពុជា។ ជាអាទិ៍ Blunt and Turner (2005 សូមមើល Turner 2002 ផងដែរ) បានលើកថា វប្បធម៌បែបឋានានុក្រម និងបណ្តាញខ្សែខ្នងចាក់ឫសយ៉ាងជ្រៅក្នុងសង្គម

---

១ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI មួយនិពន្ធដោយ លោក ហេង សីហា លោក គឹម សេតារា និង លោក សូ សុខប៊ុនធឿន (ជិតចេញផ្សាយ) ស្តីពី *អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យក្នុងប្រព័ន្ធនយោបាយបែបកូនកាត់៖ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងបរិបទប្រទេសកម្ពុជា*។ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងបរិបទប្រទេសកម្ពុជា មានន័យថាការសន្មតទៅតាមទ្រឹស្តី គឺមិនអាចសម្រេចបានទេ ដោយសារលទ្ធផលនៃដំណើរការកំណែទម្រង់បានផ្លាស់ប្តូរនៅក្នុងបរិបទមូលដ្ឋាន។

២ មកពីកម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ នៃវិទ្យាស្ថាន CDRI។

បានបង្កើតនូវ ទម្រង់វិមជ្ឈការមួយដែលមានលក្ខណៈទន់ខ្សោយ (សូមមើល Smoke & Morrison 2008: 19-20, 22)។

វប្បធម៌ និងលំនាំបែបឋានានុក្រម និងបណ្ដាញខ្សែខ្នង លើកឡើងដោយក្រុមទី១ ខាងលើនេះ អាចជាកត្តារាំងស្ទះដល់កំណែទម្រង់វិមជ្ឈការ រួមមានបញ្ហាផ្សេងៗ ដូចជា បញ្ហាកិច្ចសហការរវាងមន្ទីរជំនាញ និងរដ្ឋបាលមូលដ្ឋាន ភាពយឺតយ៉ាវនៃការផ្ដល់សិទ្ធិអំណាចក្នុងការសម្រេចចិត្ត មកពីក្រសួងជំនាញទៅឲ្យក្រុមប្រឹក្សាឃុំ ស្វ័យភាពមិនពេញលេញសម្រាប់ក្រុមប្រឹក្សាឃុំ (ដូចមានចែងក្នុងបញ្ញត្តិច្បាប់) ការបែងចែកតួនាទីមិនច្បាស់លាស់រវាងគណបក្សនយោបាយ និងរដ្ឋ (ឥទ្ធិពលគណបក្សនយោបាយ) និងបញ្ហាគណនេយ្យភាព បង្កឡើងដោយអតុល្យភាពនៃអំណាច ដោយមន្ត្រីទទួលបានតំណែងតាមការចាត់តាំង តែងមានអំណាច ច្រើនជាងមន្ត្រីជ្រើសតាំងឡើងតាមការបោះឆ្នោតពីប្រជាជន។ ប៉ុន្តែទស្សនៈនេះសង្កត់ធ្ងន់ខ្លាំងពេកលើការមិនវិវត្ត ឬមិនផ្លាស់ប្ដូរនៃវប្បធម៌នយោបាយកម្ពុជា និងថែមទាំងមិនទទួលស្គាល់ភាពជោគជ័យនានា ដែលសម្រេចបានមកដល់បច្ចុប្បន្ន (Hughes &Öjendal 2006)។ ការសិក្សាមួយចំនួនផ្សេងទៀតបង្ហាញថា វិមជ្ឈការអាចដំណើរការស្របតាមបរិបទសង្គម-នយោបាយខុសៗគ្នាបាន ហើយវប្បធម៌របស់ប្រទេសនីមួយៗ ក៏មិនមែននៅនឹងថ្កល់នោះទេ ប៉ុន្តែអាចប្រែប្រួលសន្សឹមៗ នៅក្នុងបរិយាកាសនយោបាយដែលកំពុងផ្លាស់ប្ដូរ។ ផ្អែកលើបទពិសោធន៍ច្រើនឆ្នាំរបស់ខ្លួន នៅប្រទេសមួយចំនួនជាពិសេសប្រទេសឥណ្ឌា លោក Manor (2008: 3) បានបង្ហាញថា "ឋានានុក្រម" និង "បណ្ដាញខ្សែខ្នង" ដែលចាក់ឫសជ្រៅក្នុងសង្គម មិនមែនជាឧបសគ្គរាំងស្ទះដល់កិច្ចប្រឹងប្រែងលើកកម្ពស់របបប្រជាធិបតេយ្យនៅមូលដ្ឋាននោះទេ ហើយប្រព័ន្ធវិមជ្ឈការនៅតែអាចដំណើរការបានល្អ។

ក្រុមទី២ មានទស្សនៈវិជ្ជមានច្រើនចំពោះកំណែទម្រង់ ដោយបានអះអាងថា វិមជ្ឈការជាឧបករណ៍សមស្របសម្រាប់ស្ដារ និងកសាងភាពស្របច្បាប់របស់រដ្ឋ នៅប្រទេសកម្ពុជាឡើងវិញ។ វិមជ្ឈការ ក៏ត្រូវបានចាត់ទុកជា "នយោបាយទន់ភ្លន់" ដែលនាំឲ្យមានការផ្លាស់ប្ដូរខាងនយោបាយ ការពង្រឹងស្ថាប័នរដ្ឋឡើងវិញ និងការបើកផ្លូវសម្រាប់ការពង្រឹងរបបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅកម្ពុជា (Öjendal & Kim 2011; Kim 2011; Kim & Öjendal 2009; Ann 2008; Manor 2008)។

អត្ថបទនេះ ពិនិត្យឡើងវិញអំពីផលសម្រេច និងបញ្ហាប្រឈមនៃកំណែទម្រង់វិមជ្ឈការនៅកម្ពុជា មកទល់បច្ចុប្បន្ន។ ដោយមិនបដិសេធចោលទាំងស្រុងនូវឧបសគ្គលើកឡើង ដោយក្រុមទី១ ខាងលើ ការសិក្សានេះទទួលស្គាល់ថា កំណែទម្រង់វិមជ្ឈការនៅកម្ពុជា បានធ្វើឡើងក្នុងបរិយាកាសនយោបាយបែបកូនកាត់។ បរិយាកាសនយោបាយបែបកូនកាត់នេះ ជាស្ថានភាពមួយដែលទម្រង់នៃប្រព័ន្ធប្រជាធិបតេយ្យសេរីនិយម ដូចជា នីតិរដ្ឋ និងស្ថាប័នផ្លូវការផ្សេងៗ ត្រូវបានផ្សារភ្ជាប់ជាមួយស្ថាប័ន និងវប្បធម៌នយោបាយប្រពៃណីនៅមូលដ្ឋាន (Van de Walle 2001; Diamond 2002)។ វាបង្ហាញពីការផ្លាស់ប្ដូរមួយដែលកើតមានឡើងក្នុងស្ថានភាពនយោបាយមួយ ដែលលោក Carothers (2002) ពិពណ៌នាថាជា "ដំណាក់កាលពណ៌ប្រផេះ (Grey Zone)"។ ដំណាក់កាលពណ៌ប្រផេះនេះ គឺជាដំណាក់កាលមួយនៅចន្លោះរវាង "របបប្រជាធិបតេយ្យពេញលេញ និងរបបផ្ដាច់ការទាំងស្រុង" នៅពេលប្រទេសមួយធ្វើអន្តរកាលចេញពីរបបផ្ដាច់ការ។ ក្នុងស្ថានភាពបែបនេះ គេមិនអាចរំពឹងថាដំណើរការកសាងរបបប្រជាធិបតេយ្យអាចលូតលាស់ទៅមុខយ៉ាងរលូននោះទេ ដោយសារបញ្ហាប្រឈមនានាអាចរំពឹងថានឹងកើតមានឡើង ដូចជា ប្រភេទផ្សេងៗនៃស្ថាប័នក្រៅផ្លូវការ ទំនោរខាងវប្បធម៌ប្រពៃណីបង្កើតថ្មី និងបណ្ដាញជាប់និន្នាការនយោបាយផងដែលភាគច្រើនគ្មានលក្ខណៈប្រជាធិបតេយ្យ ឬប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យតែម្ដង (CDRI 2006: 16)។ ទោះយ៉ាងនេះក្ដីក៏មិនគួរធ្វើការវាយតម្លៃថា ការប្រែប្រួលនៅមូលដ្ឋានគ្មានផលវិជ្ជមានដល់កំណែទម្រង់នោះទេ។ ការសិក្សានេះមានទស្សនៈស្រដៀងគ្នាមួយជាមួយនឹងក្រុមទី២ អំពីសន្ទុះ និងភាពជោគជ័យដែលអាចសម្រេចបានពីកំណែទម្រង់វិមជ្ឈការ ប៉ុន្តែការសិក្សានេះក៏បានដាស់តឿនថា ជាទូទៅ ភាពជោគជ័យនៃវិមជ្ឈការអាចទទួលបានទៅតាមលក្ខខណ្ឌមូលដ្ឋានផ្សេងៗគ្នា ហើយប្រែប្រួលនៅក្នុងបរិបទនយោបាយបែបកូនកាត់ ដែលនាំឲ្យមានលទ្ធផលសម្រេចបានមិនស្មើគ្នា។

## លទ្ធផលសំខាន់ៗ

### *គណនេយ្យភាព និងការឆ្លើយតប*

ក្រោយបានអនុវត្តកំណែទម្រង់ជាងមួយទសវត្សរ៍មក គេអាចឃើញច្បាស់ពីការរីកចម្រើនខ្លះៗ នៅក្នុងគណនេយ្យភាព និងការឆ្លើយតបរបស់ក្រុមប្រឹក្សា ចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ ទាំងក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ បានរាយការណ៍ពីភាពប្រសើរឡើងយ៉ាងច្បាស់នៅក្នុងគណនេយ្យភាព និងការផ្ដល់សេវាកម្ម។ ក្រុមប្រឹក្សាឃុំ មានទំនួលខុសត្រូវចំពោះប្រជាពលរដ្ឋ ហើយអនុវត្តតួនាទី ឬអាណត្តិរបស់ខ្លួនដោយផ្អែកលើគោលការណ៍នៃគណនេយ្យភាព។ ប្រជាពលរដ្ឋមូលដ្ឋានយល់ថា ខ្លួនទទួលបានសិទ្ធិអំណាចពីដំណើរការវិមជ្ឈការ ដោយអាចទាមទារគណនេយ្យភាពពីថ្នាក់ដឹកនាំ ដែលជាប់ឆ្នោតបាន តាមរយៈការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួន ក្នុងការបោះឆ្នោតទម្លាក់ពីតំណែងនូវសមាជិកក្រុមប្រឹក្សាណាដែលអសមត្ថភាព។

ស្របគ្នានេះដែរ គេក៏សង្កេតឃើញមានកំណើនការឆ្លើយតបពីថ្នាក់ដឹកនាំនៅមូលដ្ឋាន។ ប៉ុន្តែការរីកចម្រើននៃគណនេយ្យភាព និងការឆ្លើយតបនេះ ប្លែកបន្តិចពីការសន្មតទូទៅ តាមទ្រឹស្ដីនៃវិមជ្ឈការតាមបែបប្រជាធិបតេយ្យ។ វិធីប្រតិបត្តិរបស់រដ្ឋបាលមូលដ្ឋាន នៅតែបន្តដូចមុនគឺ វិន័យគណបក្សនយោបាយនៅតែខ្លាំង ដែលជាសម្ពាធដល់គណនេយ្យភាពពីលើចុះក្រោម។ ការឆ្លើយតបរបស់ក្រុមប្រឹក្សាឃុំកន្លងមក ផ្អែកលើសមត្ថភាពផ្ទាល់ខ្លួនក្នុងការប្រមែប្រមូលជំនួយពីខាងក្រៅ ដើម្បីបន្ថែមលើថវិកាឃុំ/សង្កាត់ ដែលពុំគ្រប់គ្រាន់សម្រាប់ឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍នៅមូលដ្ឋាន។ នៅចំពោះមុខកង្វះខាតធនធានបែបនេះ លទ្ធភាពរបស់ថ្នាក់ដឹកនាំមូលដ្ឋានក្នុងការទទួលខុសត្រូវ និងឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ត្រូវពឹងផ្អែកលើបុគ្គលិកលក្ខណៈ និងជំនាញផ្ទាល់ខ្លួន ដើម្បីទទួលបានធនធានពីប្រភពផ្សេងទៀត សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍ក្នុងមូលដ្ឋាន តាមរយៈការអំពាវនាវទៅគណបក្សនយោបាយ សប្បុរសជន និងប្រភពដទៃទៀត។ ទំនាក់ទំនងបុគ្គល និងបណ្ដាញខ្សែខ្នងដែលគេតែងគិតថាជាប្រភពនៃអំពើពុករលួយ ក៏បានយកមកប្រើប្រាស់ដែរ ដើម្បីទទួលបានមូលនិធិសម្រាប់ការផ្ដល់សេវាសាធារណៈ។ ប៉ុន្តែការពឹងផ្អែកលើប្រភពមូលនិធិក្រៅផ្លូវការបែបនេះ បានចោទសំណួរជាច្រើនលើការពង្រីកគណនេយ្យភាព ព្រោះគេមិនច្បាស់ទេថា តើមូលនិធិក្រៅផ្លូវការទាំងនោះ មានប្រភពមកពីណា។ ឧបសគ្គកាន់តែធំចំពោះការឆ្លើយតប និង

គណនេយ្យភាពរបស់រដ្ឋបាលមូលដ្ឋាន តែងកើតមាននៅតំបន់សម្បូរធនធាន ច្រើនជាងតំបន់ខ្សត់ធនធាន។ តួយ៉ាង ក្រុមប្រឹក្សាឃុំដែលយកចិត្តទុកដាក់ និងធានាឲ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងគាំទ្រប្រជាពលរដ្ឋក្នុងការប្រឆាំងនឹងបទល្មើសធនធានធម្មជាតិ តាមជាក់ស្តែងពុំមានសិទ្ធិអំណាចពិតប្រាកដដើម្បីសម្រេចចិត្ត និងគ្រប់គ្រងទេ។ ការលំបាកភាគច្រើនលើបញ្ហាធនធានធម្មជាតិ ជារឿយៗ ស្ថិតនៅក្រៅក្របខ័ណ្ឌនៃវិមជ្ឈការ និងវិសហមជ្ឈការ ។

*ការចូលរួមរបស់ប្រជាពលរដ្ឋ*

វិមជ្ឈការ បានបើកផ្លូវឲ្យប្រជាពលរដ្ឋចូលរួមក្នុងកិច្ចការនយោបាយ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗនៅមូលដ្ឋាន។ បច្ចុប្បន្ន ប្រជាពលរដ្ឋទទួលបានការអនុញ្ញាតឲ្យជ្រើសរើសថ្នាក់ដឹកនាំ និងបញ្ចេញគំនិតយោបល់ទាក់ទងនឹងការអភិវឌ្ឍក្នុងមូលដ្ឋាន និងតម្រូវការរបស់សហគមន៍ ស្របតាមគោលការណ៍អភិបាលកិច្ចនៅមូលដ្ឋាន។ ទោះបីមានការវិវត្តប្រសើរឡើងបែបនេះក្តី ក៏នៅតែមានសំណួរថា តើវិមជ្ឈការពិតជាបាននាំមកនូវការចូលរួមតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋានមែន ឬយ៉ាងណា។ លទ្ធផលបានពីការសិក្សាពីមុនៗ និងការចុះអង្កេតនាពេលថ្មីៗ បង្ហាញថា នៅកម្ពុជា កត្តាវប្បធម៌ និងសេដ្ឋកិច្ច តែងកំណត់លើលក្ខណៈនៃការចូលរួមរបស់ប្រជាពលរដ្ឋ។ ស្ថានភាពរស់នៅខ្សត់ខ្សោយបង្ខំឲ្យ ប្រជាពលរដ្ឋជាច្រើននាក់ត្រូវចំណាយពេលយ៉ាងច្រើនក្នុងការរកចំណូល ជាជាងចូលរួមក្នុងសកម្មភាពសាធារណៈ ឬការអភិវឌ្ឍសហគមន៍ ហើយកត្តាសេដ្ឋកិច្ចទន់ខ្សោយនេះ ក៏ជំរុញឲ្យពួកគាត់សម្លឹងរកផលប្រយោជន៍ភ្លាមៗ (ឧទាហរណ៍អំណោយ) ពីគ្រប់ទម្រង់នៃការចូលរួមក្នុងសហគមន៍។ ដោយសារក្រុមប្រឹក្សាឃុំ ពុំមានលទ្ធភាពឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ហេតុនេះប្រជាពលរដ្ឋក៏បាត់បង់ចំណាប់អារម្មណ៍ចូលរួមក្នុងការងារនៅមូលដ្ឋាន។ នៅពេលប្រជាពលរដ្ឋចូលរួមក្នុងការប្រជុំ ពួកគាត់អាចនឹងបញ្ចេញមតិពាក់ព័ន្ធនឹងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋានមិនបានពេញលេញទេ ដោយសារការរារាំងពីបញ្ហាវប្បធម៌បែបឋានានុក្រម។

*ភាពជាតំណាង*

វិមជ្ឈការ ក៏បានបើកឱកាសខាងនយោបាយផងដែរ សម្រាប់ការកែលម្អភាពជាតំណាង នៅកម្រិតមូលដ្ឋាននៃគណបក្សនយោបាយ និងក្រុមប្រជាពលរដ្ឋមានភាពទន់ខ្សោយ រួមទាំងស្ត្រីផង។ ភាពជាតំណាង (ឧទាហរណ៍ ការបង្កើតក្រុមប្រឹក្សាឃុំតាមការបោះឆ្នោត) មិនត្រឹមតែឆ្លុះបញ្ចាំងនូវការយល់ដឹងពីគោលការណ៍ប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយតភ្ជាប់គម្លាតរវាងរដ្ឋ/អាជ្ញាធរ និងប្រជាពលរដ្ឋទៀតផង។ ទោះបីបរិយាកាសអភិបាលកិច្ចនៅមូលដ្ឋានបានផ្លាស់ប្តូរ និងល្អប្រសើរឡើងដូច្នេះក្តី ក៏នៅតែមានសំណួរថា តើភាពជាតំណាងមានលក្ខណៈជ្រាលជ្រៅយ៉ាងណាទៅលើនយោបាយ និងកិច្ចការអភិវឌ្ឍន៍ក្នុងមូលដ្ឋាន។ គណបក្សប្រឆាំងទំនងជាមិនអាចពង្រឹងវត្តមានរបស់ខ្លួននៅតាមមូលដ្ឋានទេ ដោយសារតែធនធាន និងកម្លាំងខាងនយោបាយរបស់ខ្លួននៅមានកម្រិត។ ស្រដៀងគ្នានេះដែរ កំណើនភាពជាតំណាងនៃស្ត្រីភេទ មិនមែនបានន័យថាពួកគេមានអំណាចខាងនយោបាយច្រើនជាងមុនទេ ដោយសារមានឧបសគ្គខាងសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។ ឧបសគ្គទាំងនេះមានដូចជា បន្ទុកគ្រួសារ ការអប់រំមានកម្រិត កង្វះភាពក្លាហានក្នុងការការពារគំនិតខ្លួនកង្វះជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុនិងឋានានុក្រមតាមវប្បធម៌ចាស់ៗ។ ស្ត្រីកម្រត្រូវបានគេចាត់តាំងឲ្យធ្វើការងារអ្វីសំខាន់ៗ ក្រៅតែពីការទទួលខុសត្រូវលើកិច្ចការនារី និងកុមារ។ ម្យ៉ាងទៀត ភាពជាតំណាងក្នុងមជ្ឈដ្ឋាននយោបាយពឹងផ្អែកយ៉ាងខ្លាំងទៅលើគណបក្សនយោបាយនីមួយៗ ព្រោះប្រព័ន្ធបោះឆ្នោតបច្ចុប្បន្ន ជាប្រព័ន្ធសមាមាត្រផ្អែកលើបញ្ជីរបស់គណបក្ស ហើយលំដាប់ឈ្មោះរបស់បេក្ខជនក្នុងបញ្ជីនេះផ្អែកលើអាទិភាព ការលើកទឹកចិត្ត និងឆន្ទៈខាងនយោបាយរបស់ថ្នាក់ដឹកនាំគណបក្សនីមួយៗ។ នាពេលបច្ចុប្បន្ន នៅក្នុងគណបក្សនយោបាយនីមួយៗ ឆន្ទៈនយោបាយក្នុងការលើកកម្ពស់តួនាទីរបស់ស្ត្រីភេទ នៅមានកម្រិតនៅឡើយ។

## មាគ៌ាឆ្ពោះទៅមុខ

លទ្ធផលនៃកំណែទម្រង់វិមជ្ឈការមកដល់បច្ចុប្បន្ននេះ បង្ហាញពីលក្ខណៈខ្លះ ស្របតាមវិមជ្ឈការតាមបែបប្រជាធិបតេយ្យ និងខ្លះទៀតស្របតាមកត្តាវប្បធម៌ក្នុងស្រុករបស់កម្ពុជា។ គេអាចនិយាយម្យ៉ាងទៀតថា ជោគជ័យសម្រេចបាននេះ មិនមែនជាអភិបាលកិច្ចដែលមានលក្ខណៈវិមជ្ឈការតាមបែបប្រជាធិបតេយ្យពេញលេញនោះទេ ប៉ុន្តែអាចហៅតាមពាក្យរបស់លោក David Robert ថាជា "ការអនុវត្តតាមបែបប្រជាធិបតេយ្យដោយកែសម្រួលទៅតាមបរិបទរបស់ម្ចាស់ស្រុក (indigenized democratic practice)" (Roberts 2008)។ បញ្ហាថា តើវិមជ្ឈការតាមបែបប្រជាធិបតេយ្យ នឹងវិវត្តហួសពីដំណាក់កាលនេះទៀតឬយ៉ាងណា កំពុងស្ថិតក្នុងការជជែកវែកញែកនៅឡើយ។ ការកសាងរបបប្រជាធិបតេយ្យ មិនមែនជាកិច្ចការសាមញ្ញទេ។ ទោះយ៉ាងនេះក្តី កំណែទម្រង់វិមជ្ឈការមកទល់ពេលនេះ បានសម្រេចនូវការងារជាមូលដ្ឋានគ្រឹះ ដើម្បីកសាង និងអភិវឌ្ឍរបបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ដូចជា៖

- កំណែទម្រង់វិមជ្ឈការ បានជួយបង្កើតរបបនយោបាយពហុបក្ស ជាពិសេសក្រុមប្រឹក្សាពហុបក្ស នៅកម្រិតមូលដ្ឋានតាមរយៈការបោះឆ្នោត។ កំណែទម្រង់នេះ ក៏បានជួយផ្សះផ្សាការខ្វែងមតិខាងនយោបាយ និងជួយសម្រុះសម្រួលភាពខុសគ្នាខាងមនោគមវិជ្ជា ដើម្បីសម្រេចគោលដៅនៃការអភិវឌ្ឍមូលដ្ឋានរួម។
- វិមជ្ឈការ បានរួមចំណែកជួយបង្កើនភាពស្របច្បាប់ខាងនយោបាយនៃរបបគ្រប់គ្រង ដោយលើកកម្ពស់ឡើងវិញនូវតួនាទីនៃរចនាសម្ព័ន្ធរបស់រដ្ឋ នៅកម្រិតមូលដ្ឋាន ដែលគេមិនបានយកចិត្តទុកដាក់ជាយូរមកហើយ ដោយសារការវឹកវរខាងនយោបាយ និងសង្គ្រាមស៊ីវិល។ នៅក្រោមកំណែទម្រង់នេះ ស្ថាប័ននយោបាយមូលដ្ឋាន គេបានសើរើរៀបចំរចនាសម្ព័ន្ធ និងគិតគូរបង្កើតឡើងវិញ។ អាជ្ញាធរមូលដ្ឋានក៏បានទទួលសិទ្ធិអំណាចក្នុងកម្រិតមួយ ដើម្បីក្លាយជាភ្នាក់ងារ ឬតួអង្គក្នុងការអភិវឌ្ឍមូលដ្ឋាន។
- វិមជ្ឈការបានភ្ជាប់គម្លាតរវាងប្រជាពលរដ្ឋ និងរដ្ឋ។ តាំងពីមានកំណែទម្រង់មក បរិយាកាសប្រកបដោយការភ័យខ្លាច ការគាបសង្កត់ និងការបង្ខិតបង្ខំ ក៏បានរលាយបាត់ជាបណ្តើរៗ។ Öjendal and Kim (2006: 157-158) បានវែកញែកថា គំនិតរបស់ប្រជាពលរដ្ឋបង្ហាញនូវការគោរពកោតខ្លាច អាជ្ញាធរមូលដ្ឋានក៏បានប្រែប្រួលដែរ។ កាលពីមុន នៅក្នុងទំនាក់ទំនងជាមួយអាជ្ញាធរ អ្នកភូមិតែងមានការភ័យខ្លាចច្រើន ហើយមានការគោរព និងការកោតតិចតួចណាស់។ ប៉ុន្តែ

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@cdri.org.kh
គេហទំព័រ៖ http://www.cdri.org.kh

បច្ចុប្បន្ននេះ អ្នកភូមិមានការគោរពច្រើនជាងការកោត និងការភ័យខ្លាច។

- វិមជ្ឈការ ហាក់មិនស៊ីគ្នាទេជាមួយនឹងវប្បធម៌បែបឋានានុក្រម និងគ្មានការចូលរួមពីប្រជាជន ប៉ុន្តែវិមជ្ឈការជួយឲ្យអ្នកបោះឆ្នោត និងមន្ត្រីជាប់ឆ្នោតបានជ្រួតជ្រាបពីគុណតម្លៃតាមបែបប្រជាធិបតេយ្យ។ តាមរយៈការអប់រំផ្នែកនយោបាយ អ្នកជាតំណាង ឬដឹកនាំដែលជាប់ឆ្នោតសព្វថ្ងៃ បានដឹងច្បាស់ថាអ្នកដឹកនាំត្រូវមានគណនេយ្យភាពចំពោះប្រជាជន ត្រូវមានការឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍មូលដ្ឋាន ត្រូវទាក់ទាញឲ្យប្រជាជនមកចូលរួម ក្នុងការងារអភិវឌ្ឍន៍សហគមន៍ និងត្រូវចេញមុខតំណាងផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន។

ការពង្រឹងបន្ថែមនូវវិមជ្ឈការតាមបែបប្រជាធិបតេយ្យ ទាមទារឲ្យមានកត្តាជួយសម្រួលជាច្រើន ដូចជា៖

- ការផ្តល់អំណាចដល់ក្រុមប្រឹក្សាមូលដ្ឋាន ឲ្យមានលទ្ធភាពកាន់តែប្រសើរ ដើម្បីប្រើប្រាស់ធនធានផ្លូវការ និងកាត់បន្ថយការពឹងផ្អែកទៅលើប្រភពមូលនិធិក្រៅផ្លូវការ នៅក្នុងការងារអភិវឌ្ឍន៍មូលដ្ឋាន។
- ការកែលម្អការអប់រំ និងការចូលរួមរបស់ប្រជាជន ក្នុងការទាមទារគណនេយ្យភាព និងអភិបាលកិច្ចល្អពីអាជ្ញាធរថ្នាក់ក្រោមជាតិ និងក្រសួងជំនាញ។
- ការពង្រឹងការសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធ និងអាជ្ញាធរដែនដីនៅថ្នាក់ក្រោមជាតិ នៅក្រោមក្របខ័ណ្ឌរដ្ឋបាលឯកភាព ដើម្បីលើកកម្ពស់គណនេយ្យភាព និងការផ្តល់សេវាកម្ម។
- ការកែលម្អសមត្ថភាពថ្នាក់ដឹកនាំ នៅថ្នាក់ក្រោមជាតិ (ជាពិសេសនៅថ្នាក់ស្រុក) ដើម្បីជួយឲ្យរដ្ឋបាលឯកភាពអាចដំណើរការបានល្អ។

## ឯកសារយោង

Ann, Sovatha (2008), "Patron-Clientelism and Decentralization: An Emerging Local Political Culture in Rural Cambodia", Master of Art thesis (Northern Illinois University)

Blunt, Peter & Mark Turner (2005), "Decentralization, Democracy and Development in a Post-Conflict Society: Commune Councils in Cambodia", *Public Administration and Development* 25, pp. 75-87

Carothers, Thomas (2002), "The End of the Transition Paradigm", *Journal of Democracy* 13(1), pp. 5-21

CDRI (2006), *KECHHNAY: Strengthening the State, Empowering Citizens for Democratic Development* (Phnom Penh: CDRI)

Diamond, Larry (1999), *Developing Democracy: Toward Consolidation*, (Baltimore, Maryland: The Johns Hopkins University Press: Baltimore and London)

Hughes, Caroline & Joakim Öjendal (2006), "Cambodia: Reassessing Political Culture in Times of Political Change", *Journal of South East Asian Studies* 36 (2), pp. 415-420

Kim, Sedara (2011), "Democracy in Action: Decentralisation in Post-Conflict Cambodia", PhD dissertation (Goteborg University)

Kim, Sedara & Joakim Öjendal (2009), "Decentralization as a Strategy for State Reconstruction in Cambodia", in J. Öjendal & M. Lilja (eds.). *Beyond Democracy in Cambodia: Political Reconstruction in a Post-Conflict Society* (Copenhagen, Denmark: NIAS Press) pp.101-135

Manor, James (2008), *Supporting Cambodia's Decentralization and Deconcentration Reform: Issues and Options for Development Partners* (Phnom Penh: Sida)

Öjendal, Joakim & Sedara Kim (2006), "Korob, Kaud, Klach: In Search of Agency in Rural Cambodia", *Journal of Southeast Asia Studies* 37(3), pp. 507-526

Öjendal, Joakim & Sedara Kim (2011), *Real Democratization in Cambodia? An Empirical Review of the Potential of a Decentralization Reform* (Visby, Sweden: ICLD Swedish International Centre for Local Democracy)

Roberts, David (2008), "Hybrid Polities and Indigenous Pluralities: Advanced Lessons in State-building from Cambodia", *Journal of Intervention and State-building*, Vol. 2, pp. 63-86.

Royal Government of Cambodia (2005), *Strategic Framework for Decentralization and De-concentration Reforms* (Phnom Penh: RGC)

Smoke, Paul & Joanne Morrison (2008), "Decentralization in Cambodia: Consolidating Central Power or Building Accountability from Below?" Paper presented at the conference on Obstacles to Decentralization: Lessons from Selected Countries, Andrew Young School of Policy Studies, Georgia State Universtity, USA. http://aysps.gsu.edu/isp/files/ISP_DECENTRALIZATION_CONFERENCE_CAMBODIA_PAPER.pdf (accessed 7 September 2011)

Turner, Mark (2002), "Whatever Happened to Deconcentration? Recent Initiative in Cambodia", *Public Administration and Development* 22, pp. 353-364

Van de Walle, Nicolas (2001), *African Economies and the Politics of Permanent Crisis*, (Cambridge: Cambridge University Press)